ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF PUBLIC WORKS AND TRANSPORT

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ:០៧៩...៣៥....សក

រាជធានីភ្នំពេញ, ថ្ងៃទី២១...ខែ...ឆ្នាំ 2009

# សេចក្តីណែនាំ
## ស្តីពី
## ការប្តូរអាសយដ្ឋានរបស់អ្នកបើកបរនៅលើបណ្ណបើកបរយានយន្ត

កន្លងមក ក្រសួងសាធារណការ និងដឹកជញ្ជូន សង្កេតឃើញថា អ្នកបើកបរមួយចំនួនបានធ្វើការប្តូរអាសយដ្ឋាន ទៅរស់នៅកន្លែងផ្សេង ហើយដើម្បីងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការស្រាវជ្រាវរកអាសយដ្ឋានអ្នកបើកបរយានយន្ត ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំ អគ្គនាយកដ្ឋានដឹកជញ្ជូន និងគ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដូចខាងក្រោម :

**ក-អគ្គនាយកដ្ឋានដឹកជញ្ជូន**

១-ចេញប័ណ្ណបើកបរយានយន្តដល់អ្នកបើកបរ ដែលបានប្តូរអាសយដ្ឋានពីរាជធានីទៅរស់នៅបណ្តាខេត្ត ឬពីបណ្តា ខេត្ត ទៅរស់នៅរាជធានី ឬពីខេត្តមួយទៅរស់នៅខេត្តមួយផ្សេងទៀត ។

២-រាល់ការផ្លាស់ប្តូរអាសយដ្ឋានខាងលើនេះ ត្រូវមានការបញ្ជាក់ពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ដែលបានចេញប័ណ្ណបើកបរយានយន្តនៅអាសយដ្ឋានចាស់ ។

៣-រាល់ការចេញប័ណ្ណបើកបរយានយន្ត ត្រូវរក្សាអត្តសញ្ញាណអ្នកបើកបរ និងលេខប័ណ្ណបើកបរឱ្យនៅដដែល ប៉ុន្តែគ្រាន់ តែធ្វើការប្តូរអាសយដ្ឋានប៉ុណ្ណោះ ។

៤-ត្រូវធ្វើការកត់ត្រាអាសយដ្ឋានក្នុងសៀវភៅបញ្ជីធំដោយឡែក សម្រាប់ការប្តូរអាសយដ្ឋានឆ្លងរាជធានី ខេត្ត ឱ្យបានច្បាស់លាស់ ។

៥-ចំពោះអ្នកបើកបរត្រូវមានលិខិតបញ្ជាក់កាយសម្បទាជាថ្មី ហើយប័ណ្ណបើកបរត្រូវកំណត់សុពលភាពប្រើប្រាស់ជាថ្មីដែរ ។

**ខ-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត**

១-ត្រូវប្តូរអាសយដ្ឋានថ្មីរបស់អ្នកបើកបរយានយន្ត ដែលមានអាសយដ្ឋានស្ថិតក្នុងរាជធានី ខេត្ត របស់ខ្លួនប៉ុណ្ណោះ ។ ចំពោះការចេញប័ណ្ណនេះត្រូវធ្វើសម្រាប់តែប័ណ្ណបើកបរ ដែលបានចេញដោយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត របស់ខ្លួន ។

២-ត្រូវធ្វើការកត់ត្រាក្នុងតុល់បញ្ជីរបស់អ្នកបើកបរយានយន្ត ដែលបានប្តូរទៅរស់នៅអាសយដ្ឋានថ្មី ។

៣-ចំពោះអ្នកបើកបរត្រូវមានលិខិតបញ្ជាក់កាយសម្បទាជាថ្មី ហើយប័ណ្ណបើកបរត្រូវកំណត់សុពលភាពប្រើប្រាស់ជាថ្មីដែរ ។

ទទួលបានការណែនាំនេះ សូមឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន និងលោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ត្រូវចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

**ចម្លងជូន :**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- -ខុទ្ទកាល័យឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -សាលារាជធានី ខេត្ត
- -អគ្គនាយកដ្ឋានដឹកជញ្ជូន
- -នាយកដ្ឋានដឹកជញ្ជូនជុំវិញលោក
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ